ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Office of the Co-Prosecutors of the Extraordinary Chambers in the Courts of Cambodia
Parquet auprès des Chambres Extraordinaires au sein des Tribunaux Cambodgiens

**សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក /អ.ជ.ត.ក**
Case File/Dossier Nº. 002/19-09-2007-ECCC/SC

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jan-23, 08:00
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០២/១៩-០៩-២០០៧-អវតក/អជតក
**ដាក់ទៅ៖** ក្រសួងមហាផ្ទៃ
**ថ្ងៃដាក់៖** ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖** **សាធារណៈ**
**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ៖** **សាធារណៈ/Public**
**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖**
**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ៖**
**ឈ្មោះមន្ត្រីដែលបានពិនិត្យ៖**
**ហត្ថលេខា៖**

**សំណើសុំផ្ទេរទណ្ឌិត ខៀវ សំផន**

**<u>អ្នកដាក់ឯកសារ៖</u>**

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Fergal GAYNOR (បម្រុង)

**<u>ចម្លងជូន៖</u>**

**អង្គជំនុំជម្រះតុលាការកំពូល**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ្ជ អង្គ

Falguni DEBNATH

**ប្រធានរដ្ឋបាលស្តីទី**

ឯ.ឧ ក្រាញ់ តូនី

**អនុប្រធានរដ្ឋបាល**

Knut ROESANDHAUG

**ប្រធានមន្ទីរឃុំឃាំង អវតក**

ម៉ៅ សុភារម្យ

**មន្ត្រីទទួលបន្ទុកផ្នែកគាំពារការការពារក្តី**

គង់ សុគន្ធ (Kong Sokun)

**<u>អ្នកទទួលឯកសារ៖</u>**

**ក្រសួងមហាផ្ទៃ**

**ទណ្ឌិត**

ខៀវ សំផន

**មេធាវីការពារក្តីទណ្ឌិត**

គង់ សំអុន

Anta GUISSÉ

១. សហព្រះរាជអាជ្ញាសូមគោរពជម្រាបជូន សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា អង្គជំនុំជម្រះតុលាការកំពូល នៃអ.វ.ត.ក បានផ្តន្ទាទោស ទណ្ឌិត ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិតតាមអំណាចសាលដីកា ឯកសារ F36 ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ និង សាលដីកា ឯកសារ F76 ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២[1]។

២. នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ សហព្រះរាជអាជ្ញាបានដាក់សំណើជូន ឯកឧត្តម អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ អំពីការអនុវត្តទោសរបស់ទណ្ឌិត ខៀវ សំផន ដែលបច្ចុប្បន្នកំពុងបន្តស្ថិតក្នុងមន្ទីរឃុំឃាំង នៃ អ.វ.ត.ក រហូតទាល់មានការរៀបចំចប់សព្វគ្រប់ សំដៅសម្របសម្របសម្រួលជូន ខៀវ សំផន ទៅតាមលក្ខខណ្ឌឃុំខ្លួនសមស្របនឹងស្ថានភាពសុខភាព និងការចល័តទីរបស់គាត់[2]។

៣. នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ សហព្រះរាជអាជ្ញាបានដាក់ការសង្កេតស្តីពីលក្ខខណ្ឌនៃការអនុវត្តទោស ក្នុងនោះបានសន្និដ្ឋានថា សហព្រះរាជអាជ្ញា "នឹងអាចផ្តល់ការអនុញ្ញាតឲ្យផ្ទេរ [ខៀវ សំផន] ស្របតាមវិធាន ១១៣ នៃវិធានផ្ទៃក្នុង បានភ្លាមៗ បន្ទាប់ពីពួកគេបានទទួលការធានាពីការិយាល័យរដ្ឋបាលថានឹងអនុវត្តតាមអនុសាសន៍ចំនួនពីរខាងក្រោម៖

១. ការងាររៀបចំជាមួយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត អំពីការបន្តព្យាបាល ខៀវ សំផន ដើម្បីឱ្យគាត់ទទួលបានរបបថ្នាំ (ទាំងរបបថ្នាំទៀងទាត់ និងរបបថ្នាំបន្ថែមដែលគាត់អាចត្រូវការ) ការពិនិត្យតាមដានជាប្រចាំ និងការព្យាបាលតាមការចាំបាច់។
២. ការងារបន្តចាត់តាំងអ្នកមើលថែទាំ ដែលធ្លាប់មើលថែទាំ ខៀវ សំផន ក្នុងមន្ទីរឃុំឃាំងនៅ អ.វ.ត.ក ដើម្បីអាចឲ្យពួកគេអាចបន្តមើលថែទាំ ខៀវ សំផន នៅក្នុងទីតាំង ដែលគាត់នឹងបន្តឃុំក្នុងពន្ធនាគារខេត្តកណ្តាល។[3]

៤. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ ការិយាល័យរដ្ឋបាលបានដាក់ចម្លើយតបទៅនឹងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាស្តីពីលក្ខខណ្ឌនៃការអនុវត្តទោស ក្នុងនោះបានទទួលស្គាល់លក្ខខណ្ឌទាំងពីរខាងលើ និងបានលើកឡើងថា "ការិយាល័យរដ្ឋបាលសូមបញ្ជាក់ថា ការផ្តល់ថ្នាំចាំបាច់ដល់ ខៀវ សំផន ការពិនិត្យ

---

1 **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ផ្នែកសម្រេចសេចក្តី; **F76** សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ផ្នែកសម្រេចសេចក្តី។

2 **F80** សំណើសុំអនុវត្តទោស ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣។

3 **F81** សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាស្តីពីលក្ខខណ្ឌនៃការអនុវត្តទោស ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ កថាខណ្ឌ ៣០។

ព្យាបាល និងសេវាថែទាំចាំបាច់ នឹងបន្តឥតដាច់នៅពេលផ្ទេរគាត់ទៅពន្ធនាគារខេត្តកណ្តាល ស្របតាមសំណើរបស់សហព្រះរាជអាជ្ញា"[4]។

៥. ដូច្នេះ សហព្រះរាជអាជ្ញាពិចារណាថា ពុំចាំបាច់បន្តឃុំខ្លួនទណ្ឌិត ខៀវ សំផន ក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក ទៀតឡើយ។

៦. សហព្រះរាជអាជ្ញាបានពិភាក្សាជាមួយអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ និងប្រធានពន្ធនាគារខេត្តកណ្តាល និងបានចុះពិនិត្យទីតាំង។ សហព្រះរាជអាជ្ញាបានកំណត់ថា ក្រោយពីបានចុះពិនិត្យទីតាំងទាំងនោះ និងដោយមានការបញ្ជាក់ធានាពីការិយាល័យរដ្ឋបាល លក្ខខណ្ឌនៃការឃុំខ្លួននៅពន្ធនាគារខេត្តកណ្តាល មានលក្ខណៈសមស្របសម្រាប់ការឃុំខ្លួនទណ្ឌិត ខៀវ សំផន ក្នុងរយៈពេលនៃការអនុវត្តទោស។

## សំណើសុំ

៧. យោងតាមហេតុផលទាំងនេះ សហព្រះរាជអាជ្ញាសូមគោរពស្នើសុំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម :

ក. **អនុញ្ញាត**ឱ្យផ្ទេរទណ្ឌិត ខៀវ សំផន ពីមន្ទីរឃុំឃាំង នៃ អ.វ.ត.ក ទៅកាន់ពន្ធនាគារខេត្តកណ្តាល ស្របតាមសមត្ថកិច្ចរបស់តុលាការខេត្តកណ្តាល។ និង

ខ. **បញ្ជាក់**ថា ទណ្ឌិត ខៀវ សំផន នឹងមិនត្រូវផ្ទេរពីពន្ធនាគារខេត្តកណ្តាលទៅកាន់ពន្ធនាគារ ឬ មន្ទីរឃុំឃាំងផ្សេងទៀត ដោយគ្មានការជូនដំណឹងជាមុនដល់សហព្រះរាជអាជ្ញា ឬ អាជ្ញាធរអនុវត្តមុខងារដែលនៅសេសសល់នៃសហព្រះរាជអាជ្ញា ក្រោយ អ.វ.ត.ក បញ្ចប់ការងាររបស់ខ្លួន អនុលោមតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

សូម សម្តេចក្រឡាហោម ទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ | ជា លាង<br>សហព្រះរាជអាជ្ញា | រាជធានីភ្នំពេញ | [signature] |
| | Fergal GAYNOR<br>**(បម្រុង)** | | [signature] |

[4] **F81/1** ចម្លើយតបរបស់ការិយាល័យរដ្ឋបាលទៅនឹងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាស្តីពីលក្ខខណ្ឌនៃការអនុវត្តទោស ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ កថាខណ្ឌ ២។